ក្រុមប្រឹក្សារដ្ឋមន្ត្រី

លេខ ១៣ អន ក្រ

សាធារណរដ្ឋប្រជាមានិតកម្ពុជា

ឯករាជ្យ-សន្តិភាព-សេរីភាព-សុភមង្គល

# អនុក្រឹត្យ

## ស្តីពីការដឹកជញ្ជូនទំនិញតាម

## ផ្លូវទន្លេ និង ផ្លូវសមុទ្រ

## ក្រុមប្រឹក្សារដ្ឋមន្ត្រី

- បានឃើញរដ្ឋធម្មនុញ្ញនៃសាធារណរដ្ឋប្រជាមានិតកម្ពុជា
- បានឃើញច្បាប់ស្តីពីអង្គការចាត់តាំង និង សកម្មភាពរបស់ក្រុមប្រឹក្សារដ្ឋមន្ត្រីដែលប្រកាសអោយប្រើដោយក្រឹត្យលេខ ០៣ ក្រ ចុះថ្ងៃទី ១០ ខែកុម្ភៈឆ្នាំ ១៩៨២
- បានឃើញក្រឹត្យ ច្បាប់លេខ ០៧ ក្រ ច-ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ១៩៨២ ស្តីពីសមត្ថកិច្ច និង នីតិវិធីនៃការធ្វើច្បាប់ និង បទបញ្ញា ។
- តាមសំណើរបស់ ក្រសួងគមនាគមន៍ដឹកជញ្ជូន និង ប្រៃសណីយ៍

## សំរេច

### បទបញ្ញត្តិទូទៅ

មាត្រា១ :

ត្រូវពង្រីកអាជីវកម្មដឹកជញ្ជូនតាមផ្លូវទន្លេ និង ផ្លូវសមុទ្រដោយមធ្យោបាយ

*មាត្រា ៥ :*

*ភាគីម្ចាស់ទំនិញមានភារកិច្ច :*

ក - ធ្វើផែនការដឹកជញ្ជូនទំនិញរបស់ខ្លួន ជូនទៅភាគីម្ចាស់មធ្យោបាយជាមុនទូវ :

- គំរោងផែនការប្រចាំឆ្នាំថ្មី ត្រូវធ្វើអោយបានក្នុងត្រីមាសទី ៤
- គំរោងផែនការប្រចាំត្រីមាស ត្រូវផ្ញើអោយបាន ១ ខែមុនដើមត្រីមាសនិមួយ ៗ
- គំរោងផែនការប្រចាំខែ ត្រូវផ្ញើអោយបាន ១៥ ថ្ងៃមុនដើមខែ

ខ - ចុះកិច្ចសន្យាជាមួយភាគីម្ចាស់មធ្យោបាយ ដើម្បីដឹកជញ្ជូនទំនិញរបស់ខ្លួន

គ - ត្រៀមប្រមូលទំនិញទៅតាមកន្លែងកំណត់អោយបានគ្រប់ចំនួន ស្របតាមកិច្ចសន្យាដឹកជញ្ជូន ដើម្បីប្រគល់អោយភាគីម្ចាស់មធ្យោបាយ ។

ឃ - ប្រកាសបរិមាណ ប្រភេទទំនិញអោយបានត្រឹមត្រូវ

ង - ទទួលផ្ទុកនិងរើទំនិញ ក្នុងករណីដែលគ្មានចែងក្នុងកិច្ចសន្យាដឹកជញ្ជូន

ច - ធានាទទួលយកទំនិញនិងធ្វើសំណុំលិខិតផ្សេង ៗ អោយបានឆាប់រហ័សទាន់ពេលវេលា មិនត្រូវទុកអោយមធ្យោបាយដឹកជញ្ជូនរង់ចាំឡើយ ។

*មាត្រា ៦ :*

ភាគីម្ចាស់មធ្យោបាយមានភារកិច្ច :

ក - ផ្តល់មធ្យោបាយដឹកជញ្ជូនអោយទាន់ពេលវេលា ស្របតាមកិច្ចសន្យាដឹកជញ្ជូនដែលបានចុះហត្ថលេខាជាមួយភាគីម្ចាស់ទំនិញ ។

ខ - ដឹកជញ្ជូន និង ប្រគល់ទំនិញអោយបានត្រឹមត្រូវ តាមពេលនិងកន្លែង កំណត់ក្នុងលិខិតដឹកជញ្ជូន ។

គ - ធានាដឹកជញ្ជូនអោយទាន់ពេលវេលា នូវទំនិញដែលឥតបានដឹងជាមុន និងក្រៅផែនការរបស់រដ្ឋ ពេលដែលមានបញ្ជាពីក្រុមប្រឹក្សារដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងគមនាគមន៍ដឹកជញ្ជូន និង ប្រៃសណីយ៍ ឬ គណៈកម្មាធិការប្រជាជនបដិវត្តខេត្ត ក្រុង ។

ឃ - ធានាគ្រប់ និងថែរក្សាទំនិញដែលនៅក្នុងមធ្យោបាយដឹកជញ្ជូន

*មាត្រា៧:*

ភាគីម្ចាស់ទំនិញ និង ភាគីម្ចាស់មធ្យោបាយអាចចាត់តាំងតំណាងរបស់ខ្លួន ដើម្បីប្រគល់-ទទួល និង ដឹកជញ្ជូនទំនិញ ។

តំណាងរបស់ភាគីម្ចាស់ទំនិញត្រូវមានលិខិតប្រគល់សិទ្ធិពីម្ចាស់ទំនិញ ។

តំណាងរបស់ភាគីម្ចាស់មធ្យោបាយ គឺអ្នកទទួលខុសត្រូវនៅលើមធ្យោបាយ ដឹកជញ្ជូន ។

ភាគីម្ចាស់ទំនិញ និង ភាគីម្ចាស់មធ្យោបាយ ត្រូវទទួលខុសត្រូវទាំងស្រុងចំពោះ សកម្មភាពរបស់តំណាងខ្លួន ក្នុងការទាក់ទងដឹកជញ្ជូន ក៏ដូចជាការអនុវត្តកិច្ចសន្យា ដឹកជញ្ជូនដែល ភាគីទាំងពីរ បានចុះហត្ថលេខាព្រមព្រៀងគ្នា ។

## ជំពូកទី ៣ :

## ការប្រគល់ និង ទទួលទំនិញ

### មាត្រា ១១ :

យោលទៅតាមប្រភេទទំនិញ ភាគីទាំងពីរត្រូវព្រមព្រៀងគ្នាតាមកិច្ចសន្យាដឹកជញ្ជូន ហើយសរសេរបញ្ចូលក្នុងលិខិតដឹកជញ្ជូន នូវរបៀបប្រគល់និងទទួលទំនិញ ដូចខាងក្រោម ៖

— តាមទម្ងន់
— តាមចំនួនបាវ - កែស - បាច់ - កញ្ចប់
— តាមឃ្លុប
— តាម ទំហំ
— តាមការិតបន្ទាត់ស៊ុទឹកនៃមធ្យោបាយដឹកជញ្ជូន
— តាមទីកន្លែងប្រគល់-ទទួលទំនិញ

— ការដឹកជញ្ជូនគិតទៅតាមទំងន់នៃទំនិញ ភាគីម្ចាស់មធ្យោបាយត្រូវប្រគល់អោយភាគីម្ចាស់ទំនិញវិញ គ្រប់តាមទំងន់ដែលមានចុះក្នុងលិខិតដឹកជញ្ជូន ។ ការដឹកជញ្ជូនគិតទៅតាមចំនួន បាវ - កែស-បាច់ - កញ្ចប់ ឬទំហំ ភាគីម្ចាស់មធ្យោបាយត្រូវប្រគល់អោយភាគីម្ចាស់ទំនិញវិញ គ្រប់តាមចំនួនដែលមានចុះក្នុងលិខិតដឹកជញ្ជូន ហើយបើ បាវ-កែស-បាច់ ឬ កញ្ចប់មានរូបភាពខុសពីសភាព

*មាត្រា ១៣ :*

ភាគីម្ចាស់មធ្យោបាយ ក្រោយពីបានទទួលដំណឹងពីភាគីម្ចាស់ទំនិញ អំពីទំនិញដែលត្រូវប្រគល់អោយដឹកជញ្ជូន នៅចំណតណាមួយ ពេលណាមួយទៅតាមកិច្ចសន្យានោះ ត្រូវបញ្ជូនមធ្យោបាយដឹកជញ្ជូនអោយបានស្រប និងទាន់ពេលវេលាដើម្បីដឹកជញ្ជូនទំនិញនោះ ។

*មាត្រា ១៤ :*

កន្លែងប្រគល់និងទទួលទំនិញ ត្រូវកំណត់ច្បាស់ក្នុងកិច្ចសន្យាដឹកជញ្ជូន ។ ក្នុងករណីភាគីណាមួយចង់ផ្លាស់ប្តូរ កន្លែងប្រគល់ ឬ ទទួលទំនិញ ត្រូវស្នើសុំការយល់ព្រមពីភាគីមួយទៀត ។

## *ជំពូកទី ៤*

## *ការដឹកជញ្ជូន ទំនិញ*

*មាត្រា ១៥ :*

ភាគីម្ចាស់ទំនិញ ត្រូវផ្ញើលិខិតស្នើសុំមធ្យោបាយដឹកជញ្ជូន ភ្ជាប់ជាមួយលិខិតប្រកាសប្រភេទទំនិញ បរិមាណ ឬទំហំទំនិញដែលត្រូវដឹកជញ្ជូនមួយលើកៗ ទៅភាគីម្ចាស់មធ្យោបាយអោយបាន ៣ ថ្ងៃ មុនពេលផ្ទុកទំនិញរបស់ខ្លួន ។

ភាគីម្ចាស់មធ្យោបាយ ត្រូវឆ្លើយតបនឹងលិខិតខាងលើរបស់ភាគីម្ចាស់ទំនិញ ២៤ ម៉ោងមុនពេលផ្ទុកទំនិញ ។

បើភាគីម្ចាស់មធ្យោបាយ ផ្តល់មធ្យោបាយដឹកជញ្ជូន មិនស្របតាមដំណើររបស់ភាគីម្ចាស់ទំនិញ ហើយបើទំនិញដែលត្រូវដឹកជញ្ជូន ត្រូវមានកំណត់ទ្រាប់ នោះភាគីម្ចាស់មធ្យោបាយ ត្រូវទទួលបន្ទុករកកំណត់ទ្រាប់ ។

ចំពោះប្រភេទទំនិញដែលត្រូវថែរក្សាការពារពិសេស ភាគីម្ចាស់ទំនិញត្រូវណែនាំភាគីម្ចាស់មធ្យោបាយ ក្នុងការរៀបចំទំនិញ ។

*មាត្រា ២០ :*

ចំពោះប្រភេទទំនិញដែលស្រកទំងន់ ហើយមិនទាន់បានកំណត់អំពីសមាមាត្រស្រកទំងន់ជាផ្លូវការភាគីទាំងពីរ ត្រូវឯកភាពកំណត់សមាមាត្រនោះនៅក្នុងកិច្ចសន្យាដឹកជញ្ជូន និង លិខិតដឹកជញ្ជូន ។

*មាត្រា ២១ :*

ប្រភេទទំនិញដូចខាងក្រោមនេះ ដែលភាគីម្ចាស់ទំនិញត្រូវទៅតាមភាគីម្ចាស់ទំនិញ ត្រូវសហការជាមួយភាគីម្ចាស់មធ្យោបាយ ដើម្បីថែរក្សា ការពារ ។

- ទំនិញមានតំលៃដូចជា មាស-ប្រាក់ រូបិយប័ណ្ណ បុរាណវត្ថុ-វត្ថុសិល្បៈ ផ្កាំងគំនូរ-គ្រឿងអលង្ការ ។
- សត្វរស់ដែលត្រូវថែរក្សា និង អោយចំណី
- ទំនិញឆាប់រលួយស្អុយ
- ប្រភេទទំនិញស្រកទំងន់ ដែលភាគីទាំងពីរមិនឯកភាពគ្នាក្នុងការកំណត់សមាមាត្រស្រកទំងន់

ប្រសិនបើមានតំណាងភាគីម្ចាស់ទំនិញតាមការពារទំនិញ ភាគីម្ចាស់មធ្យោបាយត្រូវសរសេរចូលក្នុងលិខិតដឹកជញ្ជូន តែមិនត្រូវគិតថ្លៃឈ្នួលជូនដំណើរផងនេះទេ ។

*មាត្រា ២២ :*

បើមានទំនិញដែលម្ចាស់ប្រកាសមិនច្បាស់លាស់ បណ្ដាលអោយខូចទំនិញឯទៀត ឬ ប៉ះពាល់ដល់សន្តិសុខនៅក្នុងមធ្យោបាយដឹកជញ្ជូន ក្នុងពេលដឹកជញ្ជូន ភាគីម្ចាស់មធ្យោបាយត្រូវចាត់វិធានការជាបន្ទាន់ ដើម្បីសង្គ្រោះទំនិញ និងធ្វើអោយមានសន្តិសុខ ។

ភាគីម្ចាស់ទំនិញ ឬ តំណាងត្រូវអនុវត្តជាបន្ទាន់នូវវិធានការខាងលើ របស់ភាគីម្ចាស់មធ្យោបាយ និងត្រូវទទួលខុសត្រូវលើផលអាក្រក់ ដែលបណ្ដាលមកពីទំនិញរបស់ខ្លួន ។

*មាត្រា ២៣ :*

ក្នុងពេលដឹកជញ្ជូន បើចរាចរត្រូវស្ទះដោយគ្រោះថ្នាក់ធម្មជាតិ ភាគីម្ចាស់មធ្យោបាយត្រូវរាយការណ៍អោយភាគីម្ចាស់ទំនិញភ្លាម និងសំណូមពរអោយភាគីម្ចាស់ទំនិញផ្ដល់យោបល់ដោះស្រាយ ។

*មាត្រា ២៤ :*

បើមានកំណែពិសេសដូចមានចែងក្នុងមាត្រា ៩ នៅក្នុងពេលដឹកជញ្ជូនភាគីម្ចាស់មធ្យោបាយត្រូវអនុវត្តកំណែននោះ តែស្ថាប័នរដ្ឋដែលកែនត្រូវទទួលខុសត្រូវលើការរើ ការថែរក្សាការពារទំនិញដែលបានដឹកជញ្ជូនមកនោះ និងជូនដំណឹងទៅ

មាត្រា ២៧ ៖

អ្នកទទួលខុសត្រូវលើមធ្យោបាយដឹកជញ្ជូន ត្រូវណែនាំខាងបច្ចេកទេស ផ្ទុកនឹងរើទំនិញ ហើយត្រូវត្រួតពិនិត្យការផ្ទុកនឹងរើនោះអោយបានដិតដល់ ដើម្បីធានាអោយមានរបៀបរៀបរយនិងសន្តិសុខ ។

ចំពោះប្រភេទទំនិញពិសេសមានតំលៃ ម្ចាស់ទំនិញត្រូវជួយណែនាំបន្ថែមនូវការផ្ទុកឬរើទំនិញ ។

មាត្រា ២៨ ៖

ក - ការផ្ទុកឬ រើទំនិញត្រូវអនុវត្តទាំងថ្ងៃបុណ្យ នឹងថ្ងៃអាទិត្យ ។

ខ - រយៈពេលផ្ទុកឬរើទំនិញ នឹងបរិមាណទំនិញត្រូវផ្អែកលើសភាពជាក់ស្តែងនៃប្រភេទមធ្យោបាយនឹងប្រភេទទំនិញ ដែលអង្គការមានសមត្ថកិច្ចបានកំណត់ ។ ក្នុងករណីអង្គការមានសមត្ថកិច្ចពុំទាន់បានកំណត់ ភាគីទាំងពីរត្រូវព្រមព្រៀងគ្នាកំណត់ក្នុងកិច្ចសន្យាដឹកជញ្ជូន នឹងលិខិតដឹកជញ្ជូនដើម្បីអនុវត្ត ។ រយៈពេលផ្ទុកឬរើទំនិញ ត្រូវគិតចាប់ពី ៣ ម៉ោង ក្រោយពេលដែលភាគីម្ចាស់មធ្យោបាយបានជូនដំណឹងទៅដល់ភាគីម្ចាស់ទំនិញ ។ បើមធ្យោបាយដឹកជញ្ជូនទៅដល់ចំណតមុនម៉ោងដែលបានជូនដំណឹងរយៈពេលផ្ទុក ឬ រើទំនិញ ត្រូវគិតចាប់ពី ៣ ម៉ោងក្រោយពេលដែលភាគីម្ចាស់មធ្យោបាយជូនដំណឹងជាថ្មីទៅដល់ភាគីវិញ

ឃ - ថ្លៃឈ្នួលដឹកជញ្ជូនត្រូវគិតទៅតាមចំងាយផ្លូវដែលដឹកជញ្ជូន ។ បើចំងាយផ្លូវមិនទាន់បានកំណត់ជាផ្លូវការ ភាគីទាំងពីរ ត្រូវយកយោបល់ចុងក្រោយរបស់មន្ទីរគមនាគមន៍ដឹកជញ្ជូននិងប្រៃសណីយ៍ ខេត្ត-ក្រុង ដើម្បីគិតឈ្នួល ។

ង- ក្នុងករណីមានស្ទះចរាចរ ដូចជាមានចែងក្នុងមាត្រា ២៤ បើភាគីម្ចាស់ទំនិញធ្វើសំណូមពរ អោយដឹកជញ្ជូនទំនិញត្រឡប់មកចំណតដើមវិញ ការដឹកជញ្ជូនត្រឡប់នោះមិនត្រូវគិតឈ្នួលទេ ត្រូវគិតតែថ្លៃឈ្នួលដឹកជញ្ជូនពីចំណតផ្ទុកទំនិញទៅកន្លែងដែលត្រូវស្ទះចរាចរ ។ បើភាគីម្ចាស់ទំនិញធ្វើសំណូមពរអោយចតមធ្យោបាយដឹកជញ្ជូននៅនឹងកន្លែងលើសពី ៣ ថ្ងៃឡើងទៅ ដើម្បីរង់ចាំការធ្វើចរាចរបានល្អឡើងវិញ នោះទើបគិតថ្លៃឈ្នួលរង់ចាំ ។ បើភាគីម្ចាស់ទំនិញធ្វើសំណូមពរអោយដឹកទំនិញទៅវើនៅកន្លែងផ្សេង ពីកន្លែងកំណត់ ក្នុងកិច្ចសន្យា ឬ លិខិតដឹកជញ្ជូន ថ្លៃឈ្នួលដឹកជញ្ជូនត្រូវគិតតាមចំងាយផ្លូវ ដែលដឹកជញ្ជូនថ្មីនោះ ។

*មាត្រា៣១ :*

បើកន្លែងផ្ទុក ឬរើទំនិញនៅឆ្ងាយពីកន្លែងដែលកំណត់ក្នុងកិច្ចសន្យា ឬលិខិតដឹកជញ្ជូនចាប់ពី ១ គម. ឡើងទៅ ចំពោះមធ្យោបាយដឹកជញ្ជូនគ្មានគ្រឿងយន្ត និង ចាប់ពី ២ គម.ឡើងទៅ ចំពោះមធ្យោបាយដឹកជញ្ជូនមានគ្រឿងយន្ត ភាគីម្ចាស់ទំនិញត្រូវបង់ថ្លៃឈ្នួលដឹកជញ្ជូនបន្ថែមតាមតារាងថ្លៃឈ្នួលដឹកជញ្ជូន របស់ក្រសួងគមនាគមន៍ដឹកជញ្ជូន និង ប្រៃសណីយ៍ ។

គ - ទំនិញបាត់បង់លើសពីសមាមាត្រដែលកំណត់ក្នុងកិច្ចសន្យាដឹកជញ្ជូននឹង លិខិតដឹកជញ្ជូន ។

## *ជំពូកទី ៧*

## *ការជួសជុលសំណង*

*មាត្រា ៣៤ :*

ភាគីណាមិនគោរពតាមកិច្ចសន្យាដឹកជញ្ជូន ឬ លិខិតដឹកជញ្ជូនត្រូវជួសជុលការខូចខាតដែលបណ្តាលមកពីការមិនគោរពកិច្ចសន្យា ឬលិខិតដឹកជញ្ជូននោះ ។

*មាត្រា ៣៥ :*

ភាគីម្ចាស់មធ្យោបាយត្រូវសងចំពោះការបាត់បង់ ឬ ខូចទំនិញដែលភាគីម្ចាស់ទំនិញប្រគល់អោយខ្លួនដឹកជញ្ជូន លើកលែងតែក្នុងករណីប្រធានសក្តិ ។

*មាត្រា ៣៦ :*

ការខូចខាតទំនិញបណ្តាលមកពីការដឹកជញ្ជូនយឺតយូរ លើកលែងតែក្នុងករណីប្រធានសក្តិ ភាគីម្ចាស់មធ្យោបាយត្រូវសងទាំងស្រុង ។

*មាត្រា ៣៧ :*

ការប្រកាសមិនបានត្រឹមត្រូវតាមប្រភេទទំនិញពិតប្រាកដ ក្នុងគោលបំណងបន្ថែមផ្លៃឈ្នួលដឹកជញ្ជូន ហើយភាគីម្ចាស់មធ្យោបាយពិនិត្យឃើញក្នុងពេលដឹកជញ្ជូននោះ គូភាគីត្រូវអនុវត្តតាមកិច្ចសន្យាដែលមានចែងត្រង់ចំណុចនេះ ។

ទៅថ្នាក់ដឹកនាំនៃភាគីនោះដើម្បីដោះស្រាយ ។ បើមិនបានសំរេច ត្រូវបញ្ជូនសំណុំរឿងទៅតុលាការ ។

## ជំពូកទី ៨

## បទបញ្ញត្តិផ្តាច់ព្រ័ត្រ

*មាត្រា ៤០ :*

រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានស្ថាប័នថ្នាក់ស្មើ ក្រសួងនឹងគណៈកម្មាធិការប្រជាជនបដិវត្ត ខេត្ត-ក្រុង ត្រូវទទួលបន្ទុកអនុវត្តអនុក្រិត្យនេះ តាមភារកិច្ចរៀងៗខ្លួន ។

*មាត្រា ៤១ .*

អនុក្រិត្យនេះ មានអនុភាពគតិយុត្តិ ចាប់ពីថ្ងៃប្រកាសផ្សាយជាសាធារណៈ ។

កន្លែងទទួល : ភ្នំពេញ,ថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ១៩៨៥

- ខុទ្ទកាល័យមជ្ឈិមបក្ស ជ. ក្រុមប្រឹក្សារដ្ឋមន្ត្រី
- ខុទ្ទកាល័យក្រុមប្រឹក្សារដ្ឋ ប្រធាន

"ដើម្បីជ្រាបជាពត៌មាន" ហត្ថលេខា និង ត្រា ហ៊ុន - សែន

- ឯកសារ

ចម្លងជូន : លេខ ១២៣ ច.ល

- គ្រប់ក្រសួង-មន្ទីរជុំវិញមជ្ឈិម បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
- គ្រប់បណ្តាខេត្ត-ក្រុង ភ្នំពេញ,ថ្ងៃទី ០៤ ខែ កញ្ញា ឆ្នាំ ១៩៨៥

ដើម្បីអនុវត្ត ជ. រដ្ឋមន្ត្រីទទួលបន្ទុកខុទ្ទកាល័យក្រុមប្រឹក្សារដ្ឋមន្ត្រី

- ឯកសារ

អនុរដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

ម្សាស់ - លាស់